មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨១ ស្តីពីការប្រោសព្រះរាជទានចំពោះ លោកស្រីឧកញ៉ា **លឹម ឈីវហូ** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២៥០៧

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨២ ស្តីពីការប្រោសព្រះរាជទានប្រគេន ព្រះគ្រូបញ្ញាវិមុល **ទូច ថន** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២៥០៨

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៥ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តមចំនួន ០៤ រូប ២៥០៩

២៤-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៧ ស្តីពីការតែងតាំងឯកឧត្តម **ចៅ តុល** ជានាយករងខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ ២៥១០

២៤-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៨ ស្តីពីការតែងតាំងឯកឧត្តម **ជាម ម៉ុនណារត** និងឯកឧត្តម **ម៉ាន ណារ៉ំ** ជាទីប្រឹក្សាផ្ទាល់ សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បំណាច់ ២៥១១

២៥-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៩០ ស្តីពីការតែងតាំងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ២៥១២

២៥-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៩១ ស្តីពីការតែងតាំងព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ សិរីរត្ន** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ២៥១៣

២៥-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៩២ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និងលោកជំទាវចំនួន ០៥ រូប ២៥១៤

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

២៨-៤-២០០៦ -អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៥១៥

២៥-៤-២០០៦ -អនុក្រឹត្យលេខ ២៦៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៥១៧

២៥-៤-២០០៦ -អនុក្រឹត្យលេខ ២៧០ អនក្រ.បក ស្តីពីការជូនមេដាយសុវត្ថារា ២៥២៣

២៥-៤-២០០៦ -អនុក្រឹត្យលេខ ២៧១ អនក្រ.បក ស្តីពីការជូនមេដាយការងារ ២៥២៤

២៥-៤-២០០៦ -អនុក្រឹត្យលេខ ២៧២ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៥២៥

២៦-៤-២០០៦ -អនុក្រឹត្យលេខ ២៧៣ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៥២៦

២៧-៤-២០០៦ -អនុក្រឹត្យលេខ ២៧៤ អនក្រ.បក ស្តីពីការតែងតាំងមន្ត្រីរាជការ ២៥២៧

២៧-៤-២០០៦ -អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ស្តីពីការជូនមេដាយសហមេត្រី ២៥២៨

០២-៥-២០០៦ -អនុក្រឹត្យលេខ ២៧៦ អនក្រ.បក ស្តីពីការតែងតាំងមន្ត្រីរាជការ ២៥២៩

២~សេចក្តីសំរេច

២៥-៤-២០០៦ -សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមានិងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម ២៥៣០

III~ការងារបណ្តាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២៧-៤-២០០៦ -ប្រកាសអន្តរក្រសួងលេខ ២៨១ ប្រក.សហវ.បទ.ច.ម.ព ស្តីពីអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ២៥៣៤

២~ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រសួងយុត្តិធម៌

២៧-៤-២០០៦ -ប្រកាសរួមលេខ ១៤៥ ប្រក.កសក.កយ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូសំណុំលិខិត ដោះស្រាយបទល្មើសអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ដល់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ២៥៤២

៣~ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១៧-៣-២០០៦ -លិខិតលេខ ៧៩៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រេស្គត ហ្វ៊ររ៉ឺយូន គ្រុប អ៊ិនវេស៍ណេសិនណល លីមីធីត** ២៥៤៥

១៧-៣-២០០៦ -លិខិតលេខ ៧៩៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) យេជេន អ៊ិនវេសមេន** ២៥៤៧

១៧-៣-២០០៦ -លិខិតលេខ ៧៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.ធី.អិម អ៊ឹមផត អិចផត** ២៥៤៩

១៧-៣-២០០៦ -លិខិតលេខ ៧៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេ ស៊ី .អិម ខេ (ខេមបូឌា) ម្យូ**
ឈ្យូអែល គ្រុប ២៥៥១

១៧-៣-២០០៦ -លិខិតលេខ ៧៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីមម៉ែញ៉ូអែល (ខេមបូឌា)** ២៥៥៣

១៧-៣-២០០៦ -លិខិតលេខ ៨០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ែតវ៉ានស៍ ធេលីខម សឺវីស** ២៥៥៥

១៧-៣-២០០៦ -លិខិតលេខ ៨០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាង ឈើង អេវើ ហ្គ្រីន** ២៥៥៧

២០-៣-២០០៦ -លិខិតលេខ ៨០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីណា ឌីវេឡុបមេន អ៊ិនធើណេ**
សិនណល ២៥៥៩

២០-៣-២០០៦ -លិខិតលេខ ៨០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេន** ២៥៦១

២០-៣-២០០៦ -លិខិតលេខ ៨០៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អេស អិម ស៊ីបភីង អេជេនស៊ី** ២៥៦៣

២០-៣-២០០៦ -លិខិតលេខ ៨១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ ក្រឡាញ់** ២៥៦៥

២១-៣-២០០៦ -លិខិតលេខ ៨១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម_ប៊ីស៊ី ប៊ីលឌើរ ខនសេប** ២៥៦៧

២១-៣-២០០៦ -លិខិតលេខ ៨១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌូ លីម ខមភេនី អិលធីឌី** ២៥៦៩

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

លោកស្រី ឧកញ៉ា លឹម ឈឹវហួ

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៦០៤.១៩០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

លេខៈ ១៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ប្រគេន

ព្រះគ្រូបញ្ញាវិមុល **ឌួច ថន**

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ.ល.០៦០៤.១៩១

លេខៈ ១៩១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៧៣ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

ណាខ៊ី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្សីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

-ឯកឧត្តម អ៊ុត ឈន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

-ឯកឧត្តម សេង រ៉ុន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

-ឯកឧត្តម ចំនួ តានី

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

-ឯកឧត្តម លុក ញ៉ិប

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ល.០៦០៤.១៩៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

លេខៈ ១៩៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៨៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១៖ តែងតាំងឯកឧត្តម **ចៅ តុល** ជានាយករងខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា២៖ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣៧ល.០៦០៤.១៩៦

លេខៈ ១៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២[illegible] ខែ [illegible] ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង :

១-ឯកឧត្តម **ជាម ប៊ុនណាត** ជាទីប្រឹក្សាផ្ទាល់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភា
មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយមិនទទួលប្រាក់បំណាច់ពីរដ្ឋ ។

២-ឯកឧត្តម **ង៉ែង ណារ៉ា** ជាទីប្រឹក្សាផ្ទាល់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភា
មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយមិនទទួលប្រាក់បំណាច់ពីរដ្ឋ ។

មាត្រា២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល-០៦០៤.១៩៧

លេខ ១៩៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាអ៊ី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាសិរីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ៈ ត្រូវបានតែងតាំងឯកឧត្តមឧត្តមសេនីយ៍ឯក **តេង សាវឡុ** បច្ចុប្បន្នអនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ទៅជាអនុប្រធានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

មាត្រា២ៈ ត្រូវបានតែងតាំងឯកឧត្តមឧត្តមសេនីយ៍ឯក **លូ រ៉ាមីន** បច្ចុប្បន្នអគ្គលេខាធិការរង ទទួលបន្ទុកប្រចាំការអចិន្ត្រៃយ៍ ទៅជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា៣ៈ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៤ៈ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៥ៈ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣៧ល.០៦០៤.១៩៩

លេខៈ ១៨៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ៤ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតែងតាំងព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ សិរិរ័ត្ន** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣.រ.ល.០៦០៤.២០០

លេខ: ១៨៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ ឥន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១-ឧត្តមសេនីយ៍ឯក ឡោក ឆាយ អត្តលេខ ០០៣៦១២
ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា

២-ឧត្តមសេនីយ៍ឯក យឹម លាង អត្តលេខ ០០៥១៨២
នាយករងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

៣-ឯកឧត្តម ឡោក ហ៊ួរ នាយករងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

៤-ឯកឧត្តម មាស ណារិទ្ធ ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា

៥-លោកជំទាវ ឆោម សោភ័ណ្ឌី ជំនួយការសម្តេចប្រធានព្រឹទ្ធសភា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ខែ មេសា ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាគ្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រស.០៦០៤.២០១

លេខៈ ១៨៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាខី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១៥.០០០ លានរៀល (ដប់ប្រាំពាន់លានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌) ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយ ផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឧបត្ថម្ភរបបគោលនយោបាយជូនយោធិនប្រភេទ ២ ចំនួន ៧.៥៤៨នាក់ របស់ក្រសួងការពារជាតិ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា ៣
កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

អ៊ុក រ៉ាប៊ុន
រដ្ឋមន្ត្រីស្តីទី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការ កងទ័ពជើងគោក

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនកងឯកភាព នាយទាហាន នាយទាហានរង និងពលទាហាន នៃកងពលតូចអន្តរាគមន៍ លេខ១១ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសការងារ :

១-កងពលតូចអន្តរាគមន៍ លេខ ១១

២-ឧត្តមសេនីយ៍ត្រី	**យៀង**	**សុខុន**	០០០១២៣	មេបញ្ជាការកងពលតូចអន្តរាគមន៍ លេខ១១
៣-វរសេនីយ៍ឯក	**ផង់**	**យ៉ុត**	០០០៤៣៧	មេបញ្ជាការរងកងពល
៤-វរសេនីយ៍ឯក	**ស្វាយ**	**ញ៉ន**	០០០៤៣៨	មេបញ្ជាការរងកងពល
៥-វរសេនីយ៍ឯក	**លាត**	**សារ៉ាត់**	០០០៨២៥	មេបញ្ជាការរងកងពល
៦-វរសេនីយ៍ឯក	**សោម**	**សាភួន**	០០០៧៧១	មេបញ្ជាការរងនិងជានាយសេនាធិការកងពល
៧-វរសេនីយ៍ឯក	**តូច**	**សុផាត**	០០០៨១៨	មេបញ្ជាការរងកងពល
៨-វរសេនីយ៍ឯក	**ឡា**	**ឡៃ**	០០០៩៣៧	មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តតាកែវ
៩-វរសេនីយ៍ឯក	**ម៉ែត**	**ចាន់តារា**	០០១១៤៦	មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តកំពត
១០-វរសេនីយ៍ទោ	**ឡាន**	**ម៉ុនធឿន**	០០២៣៣០	នាយរងសេនាធិការកងពល
១១-វរសេនីយ៍ទោ	**វង្ស**	**វិយុទ្ធ**	០០១២២៩	នាយរងសេនាធិការកងពល
១២-វរសេនីយ៍ទោ	**នុត**	**ម៉ាប់**	០០២៣១១	នាយរងសេនាធិការកងពល

១៣-វរសេនីយ៍ទោ	គុយ	សំអាត	០០៩៣៤៥	នាយរងសេនាធិការកងពល
១៤-វរសេនីយ៍ទោ	ម៉ន	ម៉ៅ	០០០៨២២	នាយរងសេនាធិការកងពល
១៥-វរសេនីយ៍ទោ	ច្រាជ្ញ	សំបូរ	០០២៣០៦	មេបញ្ជាការវរសេនាតូច លេខ១១១
១៦-វរសេនីយ៍ទោ	ខុល	ញ៉ឹប	០០៩៣៤១	មេបញ្ជាការវរសេនាតូច លេខ១១២
១៧-វរសេនីយ៍ទោ	ម៉ែន	យ៉ែន	០០៩៣៤៥	មេបញ្ជាការវរសេនាតូច លេខ១១៣
១៨-វរសេនីយ៍ទោ	សែត	សុខុម	០០២៣០៨	មេបញ្ជាការវរសេនាតូច លេខ១១៤
១៩-វរសេនីយ៍ត្រី	តី	សុខេន	០០៩៣២២	នាយផ្នែកលេខាធិការកងពល
២០-វរសេនីយ៍ត្រី	គីម	កុសល	០០៩៣២៩	នាយផ្នែកហិរញ្ញវត្ថុកងពល
២១-វរសេនីយ៍ត្រី	ញៀម	សារ៉ែន	០០២២៩៩	នាយការិយាល័យទី១ កងពល
២២-វរសេនីយ៍ត្រី	អ៊ុន	ស៊ីន	០០៩៣៥១	នាយការិយាល័យទី២ កងពល
២៣-វរសេនីយ៍ត្រី	ស៊ិន	សំអឿន	០០៣៣៨៨	នាយការិយាល័យទី៣ កងពល
២៤-វរសេនីយ៍ត្រី	សោម	សុធារិន្ទ	០០២៣០២	នាយការិយាល័យទី៤ កងពល
២៥-វរសេនីយ៍ត្រី	ដួខ	ស៊ុយ	០០៩៣៣៧	នាយការិយាល័យទី៥ កងពល
២៦-វរសេនីយ៍ត្រី	ហែម	គង់	០០៩៣៣៥	នាយការិយាល័យហ្វឹកហ្វឺន កងពល
២៧-វរសេនីយ៍ត្រី	គូ	ទិត	០០៩៣៤៨	មេបញ្ជាការរងវរសេនាតូច លេខ ១១១
២៨-វរសេនីយ៍ត្រី	ទ្វិ	សារ៉ុន	០០៩៣៤៩	មេបញ្ជាការរងវរសេនាតូច លេខ ១១១
២៩-វរសេនីយ៍ត្រី	សេខ	ទុត្ថា	០០៩៤០៣	មេបញ្ជាការរងវរសេនាតូច លេខ ១១១
៣០-វរសេនីយ៍ត្រី	ទំរ	សុវណ្ណ	០០៩៣៥០	មេបញ្ជាការរងវរសេនាតូច លេខ ១១២
៣១-វរសេនីយ៍ត្រី	សាន់	ផន	០០៩៣៥៣	មេបញ្ជាការរងវរសេនាតូច លេខ ១១២
៣២-វរសេនីយ៍ត្រី	សរ	សុខ្ខ	០០៩៣៤០	មេបញ្ជាការរងវរសេនាតូច លេខ ១១៣
៣៣-អនុសេនីយ៍ឯក	ឌុំ	វណ្ណៈហេខ	០០៩៣៣១	នាយរងការិយាល័យទី១ កងពល
៣៤-អនុសេនីយ៍ឯក	ខិន	សាវី	០០៩៣៣៦	នាយរងការិយាល័យទី៤ កងពល
៣៥-អនុសេនីយ៍ឯក	ទិច	ផាន	០១៨១២៧	មេបញ្ជាការកងអនុសេនាធំ កាំភ្លើងធំកងពល
៣៦-អនុសេនីយ៍ឯក	តុល	សុបិន្ត	០១៨១៣៤	មេបញ្ជាការកងអនុសេនាធំ បញ្ជូនសារកងពល
៣៧-អនុសេនីយ៍ឯក	គាំ	សុខុម	០២៦៧៤៨	មេបញ្ជាការកងអនុសេនាធំ ដឹកជញ្ជូនកងពល
៣៨-អនុសេនីយ៍ឯក	ប៊ុល	សារឿន	០១៨១២៤	មេបញ្ជាការកងអនុសេនាធំ ស្ពានថ្នល់កងពល
៣៩-អនុសេនីយ៍ឯក	ឌុំ	សារិន	០១៨១៣២	មេបញ្ជាការកងអនុសេនាធំ ការពារកងពល
៤០-អនុសេនីយ៍ឯក	ពុ	ឈារទឿន	០១៨១០៤	មេបញ្ជាការកងអនុសេនាធំ ស៊ើបការកងពល
៤១-អនុសេនីយ៍ទោ	ប៊ិច	សំអាន	០១៨១៣៦	ជ.បុគ្គលិកវរសេនាតូច លេខ ១១១
៤២-អនុសេនីយ៍ឯក	អ៊ីខ	សុផល	០១៨១៤៦	មេបញ្ជាការកងអនុសេនាធំទី១ វ.តូច ១១១
៤៣-អនុសេនីយ៍ឯក	មាស	ថេវរ៉េត	០១៨១៣៨	មេបញ្ជាការកងអនុសេនាធំទី២ វ.តូច ១១១
៤៤-អនុសេនីយ៍ឯក	អ៊ី	ឈូ	០១៨១០៣	មេបញ្ជាការកងអនុសេនាធំគាំទ្រ វ.តូច ១១២
៤៥-អនុសេនីយ៍ឯក	សែម	វន	០១៨១៥៥	មេបញ្ជាការកងអនុសេនាធំទី៤ វ.តូច ១១២
៤៦-អនុសេនីយ៍ឯក	សឿន	សុធាវី	០១៨១២៨	មេបញ្ជាការកងអនុសេនាធំទី៦ វ.តូច ១១២
៤៧-អនុសេនីយ៍ទោ	ចាន់	ថន	០១៨១៦៧	ជ.ចលនូបត្ថម្ភ វ.តូច ១១៣
៤៨-អនុសេនីយ៍ឯក	គង់	ចាន់រឿន	០១៥៥២៩	មេបញ្ជាការកងអនុសេនាធំទី៧ វ.តូច ១១៣
៤៩-អនុសេនីយ៍ឯក	រស់	សារឿន	០១៨១៧៣	មេបញ្ជាការកងអនុសេនាធំទី៨ វ.តូច ១១៣

៥០-អនុសេនីយ៍ឯក	មុំ	ឃឿន	០១៨១៦៤	មេបញ្ជាការកងអនុសេនាធំទី៩ វ.តូច ១១៣
៥១-អនុសេនីយ៍ទោ	សន	ជាន់	០២៦៧៩៨	មេបញ្ជាការរង អធ ទី៥ វ.តូច ១១២
៥២-អនុសេនីយ៍ទោ	សារិទ្ធិ	ទន	០២៦៨១៤	មេបញ្ជាការរង អធ ទី៨ វ.តូច ១១៣

ខ-មេដាយច្រាក់ការងារ :

១-វរសេនីយ៍ត្រី	យូ	ស៊ីផុល	០១០៥២៥	មេបញ្ជាការរងវរសេនាតូច លេខ ១១១
២-វរសេនីយ៍ត្រី	សន	សុផល	០០៩៣៤៧	មេបញ្ជាការរងវរសេនាតូច លេខ ១១១
៣-វរសេនីយ៍ត្រី	ខៀវ	សារ៉ុន	០០៩៣៦២	មេបញ្ជាការរងវរសេនាតូច លេខ ១១៣
៤-វរសេនីយ៍ត្រី	ចេវ	ឃីម	០០៩៣៦១	មេបញ្ជាការរងវរសេនាតូច លេខ ១១៣
៥-វរសេនីយ៍ត្រី	មុី	សេខឃួរ	០០៩៣៦០	មេបញ្ជាការរងវរសេនាតូច លេខ ១១៤
៦-វរសេនីយ៍ត្រី	សុខ	សាវ៉ាត	០០៩៣៥២	មេបញ្ជាការរងវរសេនាតូច លេខ ១១២
៧-វរសេនីយ៍ត្រី	ជាតិ	ពិសេដ្ឋ	០០៩៣៥៧	មេបញ្ជាការរងវរសេនាតូច លេខ ១១៤
៨-វរសេនីយ៍ត្រី	នន់	វ៉ាន់ឌី	០០៩៣៥៥	មេបញ្ជាការរងវរសេនាតូច លេខ ១១២
៩-អនុសេនីយ៍ឯក	គង់	ស៊ីចាន់	០០៨០៥០	នាយរងផ្នែកលេខាធិការកងពល
១០-អនុសេនីយ៍ឯក	សៀង	សុផារ	០០៩៣២៣	ជ.ហិរញ្ញវត្ថុកងពល
១១-អនុសេនីយ៍ឯក	រស់	សារី	០០៩៣២៤	នាយឯកទេសគ្រឿងចក្រ
១២-អនុសេនីយ៍ឯក	ជាត់	សារម៉ឿន	០០៩៣២៥	នាយឯកទេសវិស្វកម្ម កងពល
១៣-អនុសេនីយ៍ឯក	លឹម	លី	០០៩៣៥១	នាយរងការិយាល័យទី២ កងពល
១៤-អនុសេនីយ៍ឯក	មាស	ម៉ុន	០០៩៣៤៣	នាយរងការិយាល័យទី២ កងពល
១៥-អនុសេនីយ៍ឯក	ហ៊ឹម	យុទ្ធពល	០០៩៣៤៦	នាយរងការិយាល័យទី៣ កងពល
១៦-អនុសេនីយ៍ឯក	ម៉ែន	សឿន	០១៨១០០	នាយរងការិយាល័យទី១ កងពល
១៧-អនុសេនីយ៍ឯក	ពេជ្រ	សុវណ្ណ	០១៨១០៨	នាយរងការិយាល័យហិរញ្ញ កងពល
១៨-អនុសេនីយ៍ទោ	ពុធ	សុវណ្ណារី	០១៨១០២	ជ.ការិយាល័យទី១ កងពល
១៩-អនុសេនីយ៍ទោ	អ៊ឹម	សាធុធ	០១៨០៨៣	ជ.ការិយាល័យទី១ កងពល
២០-អនុសេនីយ៍ទោ	ឈួន	ស៊ីផាន	០១៨១១៤	ជ.ការិយាល័យទី៤ កងពល
២១-អនុសេនីយ៍ឯក	ចាន់	ពៅ	០១៨១៥៤	ជ.ការិយាល័យទី៥ កងពល
២២-អនុសេនីយ៍ទោ	គង់	ស៊ីនួន	០១៨០៨០	ជ.លេខាធិការដ្ឋានកងពល
២៣-អនុសេនីយ៍ឯក	អុំ	ម៉ិនថារ	០១៨២២៧	នាយតិលានដ្ឋាន កងពល
២៤-អនុសេនីយ៍ឯក	ញឹម	មុរ	០១៨១៤៧	មេបញ្ជាការ អ.ធ គាំទ្រ វ.តូច ១១១
២៥-អនុសេនីយ៍ឯក	សួស	គីន	០១៨១៤២	មេបញ្ជាការ អ.ធ ទី៣ គាំទ្រ វ.តូច ១១១
២៦-អនុសេនីយ៍ឯក	សៀង	សុធារ	០១៨១៧៦	មេបញ្ជាការ អ.ធ គាំទ្រ វ.តូច ១១៣
២៧-អនុសេនីយ៍ឯក	ហ៊ីង	ចរ៉ុង	០១៨១៧៥	មេបញ្ជាការ អ.ធ ទី១១ វ.តូច ១១៤
២៨-អនុសេនីយ៍ទោ	សួស	កុសល	០២៦៧៣៩	ជ.លេខាធិការដ្ឋានកងពល
២៩-អនុសេនីយ៍ទោ	ស៊ិន	លីម	០២៦៧៤២	នាយរងការិយាល័យហិរញ្ញ កងពល
៣០-អនុសេនីយ៍ទោ	ឈុន	គឹមធន	០២៦៧៥៥	មេបញ្ជាការរងអនុសេនាធំកាំភ្លើងធំ កងពល
៣១-អនុសេនីយ៍ទោ	ខិន	ម៉ាម	០២៦៧៥៦	មេបញ្ជាការរងអនុសេនាធំកាំភ្លើងធំ កងពល
៣២-អនុសេនីយ៍ទោ	ឌី	ថន	០២៦៧៦១	មេបញ្ជាការរងអនុសេនាធំបញ្ជូនសារ កងពល
៣៣-អនុសេនីយ៍ទោ	ញួន	ចាន់សារឿន	០២៦៧៥២	មេបញ្ជាការរងអនុសេនាធំស្ពានថ្នល់ កងពល

៣៤-អនុសេនីយ៍ទោ	ហ៊ីម	សារ៉ា	០៤០៣៣០	មេបញ្ជាការរងអនុសេនាធំការពារអាកាស កងពល
៣៥-អនុសេនីយ៍ទោ	ឃៀប	ស៊ឿន	០៤០៣២៩	មេបញ្ជាការរងអនុសេនាធំការពារអាកាស កងពល
៣៦-អនុសេនីយ៍ទោ	ឃឿង	សារិន	០២៦៧៣៣	មេបញ្ជាការរងអនុសេនាធំការពារ កងពល
៣៧-អនុសេនីយ៍ទោ	ណុប	រឿន	០២៦៧៥៧	មេបញ្ជាការរងអនុសេនាធំស៊ើបការណ៍ កងពល
៣៨-អនុសេនីយ៍ទោ	សឿ	ប្រញា	០២៦៧៧១	មេបញ្ជាការរង អ.ធ គាំទ្រ វ.តូច ១១១
៣៩-អនុសេនីយ៍ទោ	ស៊ឹម	វណ្ណៈ	០៤០៤៤០	មេបញ្ជាការរង អ.ធ ទី២ វ.តូច ១១១
៤០-អនុសេនីយ៍ទោ	យាន	ស្រុង	០២៦៧៧៥	មេបញ្ជាការរង អ.ធ ទី៣ វ.តូច ១១១
៤១-អនុសេនីយ៍ទោ	គីម	លីមហេង	១៥៨៨០១	ជ.ហិរញ្ញវត្ថុ វរៈសេនាតូច លេខ ១១២
៤២-អនុសេនីយ៍ទោ	គឹម	សុខ	០២៦៧៦៧	ជ.បុគ្គលិក វរៈសេនាតូច លេខ ១១៣
៤៣-អនុសេនីយ៍ទោ	ចេង	សារ៉ា	០៤១៤៣៥	មេបញ្ជាការរង អ.ធ គាំទ្រ វ.តូច លេខ ១១៤
៤៤-នាយចំណង់	ជា	សារ៉ាត	០៤០៣៣៧	មេបញ្ជាការ អ.ត. ១ អ.ធ កាំភ្លើងធំ កងពល
៤៥-នាយចំណង់	អ៊ី	សារះឿន	០៤០៣៤១	មេបញ្ជាការ អ.ត.២ អ.ធ ស៊ើបការណ៍ កងពល
៤៦-នាយចំណង់	យឹម	សារះឿន	១៥៨៧៩២	មេបញ្ជាការ អ.ត.២ អ.ធ ស៊ើបការណ៍ កងពល
៤៧-នាយចំណង់	តូច	ម៉ិច	០៤០៣៥៥	ជ.ចលនូបត្ថម្ភ វរៈសេនាតូច លេខ ១១១
៤៨-នាយចំណង់	សំ	និត្យ	០៤០៣៧៨	មេបញ្ជាការអ.ត.ស៊ើបការណ៍វ.តូចលេខ ១១២
៤៩-នាយចំណង់	ម៉ៅ	ឌឿន	១៦១៧៣៤	មេបញ្ជាការអ.ត.១ អ.ធ ៥ វ.តូចលេខ ១១២
៥០-នាយចំណង់	គឹម	គត់	១៦១៧៤៤	មេបញ្ជាការអ.ត.២ អ.ធ ៦ វ.តូចលេខ ១១២
៥១-នាយចំណង់	កែវ	សុខា	១៥៨៨៦៦	មេបញ្ជាការអ.ត.៣ អ.ធ ៦ វ.តូចលេខ ១១២
៥២-នាយចំណង់	ម៉ែន	សារ៉ាក់	០៤០៣៤០	មេបញ្ជាការអ.តត្បាល់៨២ វ.តូចលេខ ១១៣
៥៣-ព្រិន្ទបាលឯក	ឃុត	វិចិត្រ	០៩៣៩៥៨	ជ.ការិយាល័យ ទី៥ កងពល
៥៤-ព្រិន្ទបាលឯក	នូ	វណ្ណារ៉ា	១៣៧៨២៩	មេបញ្ជាការ អ.ត.អ.ធ. បញ្ជូនសារកងពល
៥៥-ព្រិន្ទបាលឯក	អ៊ែល	សុធី	១៣៧៨៥៨	មេក្រុម .អ.ធ. បញ្ជូនសារកងពល
៥៦-ព្រិន្ទបាលឯក	ស៊ុង	សុខុម	១៥៧៤៦៦	បុ.ប្រតិបត្តិការ វ.តូចលេខ ១១១
៥៧-ព្រិន្ទបាលឯក	ទ៊ាត	អូន	១៤២៧៨៤	បុ.ចលនូបត្ថម្ភ វរសេនាតូចលេខ ១១១
៥៨-ព្រិន្ទបាលឯក	សឹង	សារះ	១៧៨៦៩៥	បុ.ចលនូបត្ថម្ភ វរសេនាតូចលេខ ១១១
៥៩-ព្រិន្ទបាលឯក	ខាន់	សារិត	១៧៨៧១០	បុ.រដ្ឋបាល វរសេនាតូចលេខ ១១១
៦០-ព្រិន្ទបាលឯក	ឃៀង	អូ	១៦១៧៣២	មេបញ្ជាការ អត. DK អ.ធ គាំទ្រ វ.តូចលេខ ១១២
៦១-ព្រិន្ទបាលឯក	ឃុត	ពៅ	១៩០៧០៥	មេបញ្ជាការ អត.៣ អធ.៤ វ.តូចលេខ ១១៣
៦២-ព្រិន្ទបាលឯក	សារិត	រ៉េត	១៥៨៧៤៩	មេក្រុម អត.៤ អធ.៨ វ.តូចលេខ ១១៣
៦៣-ព្រិន្ទបាលឯក	ឈឿង	ប្រុស	១៩០៧១១	បុ.ប្រតិបត្តិការ វ.តូចលេខ ១១៣
៦៤-ព្រិន្ទបាលឯក	យិន	យន្ត	០៦៩៩០៨	បុ.ចលនូបត្ថម្ភ អ.ធ ៧ វ.តូចលេខ ១១៣
៦៥-ព្រិន្ទបាលឯក	ទ៊ាត	ទុន	១៧៨៦៨៥	មេក្រុម អត.៣ អធ.៩ វ.តូចលេខ ១១៣
៦៦-ព្រិន្ទបាលឯក	ជិន	សារិន	១៤២៧៤៦	មេក្រុម អត. អធ. ស៊ើបការណ៍ កងពល

គ-មេដាយសិរីវឌ្ឍនការងារ :

១-អនុសេនីយ៍ទោ	ជួប	សុផាត	០១៨០៤៩	ជ.ការិយាល័យ ទី១ កងពល
២-អនុសេនីយ៍ទោ	អោក	វ៉ាយ៉ុង	០១៨០៩៩	ជ.ការិយាល័យ ទី១ កងពល
៣-អនុសេនីយ៍ទោ	យិន	យ៉ម	០១៨១៣៥	ជ.ឯកទេសបញ្ជូនសារកងពល

៤-អនុសេនីយ៍ទោ	ម៉ែន	សុខ្ខ	០២៦៧៣១	ជ.លេខាធិការដ្ឋាន កងពល
៥-អនុសេនីយ៍ទោ	ឈុន	សារី	០២៦៧៩៣	ជ.លេខាធិការដ្ឋាន កងពល
៦-អនុសេនីយ៍ទោ	អេង	សុខហៀង	០២៦៧៨១	ជ.ហិញ្ញវត្ថុ កងពល
៧-អនុសេនីយ៍ទោ	សួន	ទុន្ធី	០៤១៤៤២	ជ.ការិយាល័យ ទី២ កងពល
៨-អនុសេនីយ៍ទោ	សឿន	វាសនា	០២៦៧៥០	ជ.ការិយាល័យ ទី៣ កងពល
៩-អនុសេនីយ៍ទោ	សន	សៃហេង	០២៦៧៤៤	ជ.ការិយាល័យ ទី៤ កងពល
១០-អនុសេនីយ៍ទោ	គីម	តូច	០៤០៣៣២	មេបញ្ជាការរង អ.ធ ដឹកជញ្ជូនកងពល
១១-អនុសេនីយ៍ទោ	សេក	សារិន	០៣១៦៧១	ជ.ពេទ្យវរៈសេនាតូច លេខ ១១១
១២-អនុសេនីយ៍ទោ	ហែម	មុត	០២៦៧៥៦	មេបញ្ជាការរង អ.ធ ១០ វ.តូច លេខ១១៤
១៣-អនុសេនីយ៍ទោ	ស៊ឹម	ឡៀក	០២៦៧៥៨	មេបញ្ជាការរង អ.ធ ១២ វ.តូច លេខ១១៤
១៤-នាយចំណង់	វ៉ាន់	សំណាង	១៥៨៧៩៤	មេបញ្ជាការ អ.ត.២ អ.ធ បញ្ជូនសារកងពល
១៥-នាយចំណង់	លី	វណ្ណារ៉ុង	១៥៨៧៩៤	មេបញ្ជាការ អ.ត.១ អ.ធ បញ្ជូនសារកងពល
១៦-នាយចំណង់	យ៉ាប	ស៊ុយ	០៤០៣៣៩	មេបញ្ជាការ អ.ត.២ អ.ធ ស៊ើបការណ៍កងពល
១៧-នាយចំណង់	ខាត់	សាឯម	១៥៨៨១០	មេបញ្ជាការ អ.ត.អ.ធ ៣ វ.តូច លេខ ១១១
១៨-នាយចំណង់	ស៊ុំ	ថន	០៤០៣៤៣	មេបញ្ជាការ អ.ត.អ.ធ ៣ វ.តូច លេខ ១១១
១៩-នាយចំណង់	ម៉ុត	សឿន	០៤០៣៨៤	មេបញ្ជាការ អ.ត.១អ.ធ ៣ វ.តូច លេខ ១១២
២០-អនុសេនីយ៍ទោ	ឈូក	សុផាត	០៦៥៧៩៤	ជ.ហិរញ្ញវត្ថុ វរសេនាតូច លេខ១១៣
២១-អនុសេនីយ៍ទោ	ឌុយ	សុខុន	០៦៥៨៦៩	ជ.ហិរញ្ញវត្ថុ វរសេនាតូច លេខ១១៤
២២-នាយចំណង់	អ៊ុក	គីមយឿន	០១៧៧៩៨	ជ.បំភ័ន្តអក្ខរៈ កងពល
២៣-ព្រិន្ទបាលឯក	នេព	សុផាន	១៣៧៨០៧	ບ.ចលនូបត្ថម្ភ អ.ធ កាំភ្លើងធំកងពល
២៤-ព្រិន្ទបាលឯក	ចូវ	តេវ	១៥៨៧៨១	ប.បញ្ជូនសារ អ.ធ កាំភ្លើងធំកងពល
២៥-ព្រិន្ទបាលឯក	ស	កុស៊ុល	១៣៧៧៨៤	ជ.ការិយាល័យ ទី៤ កងពល
២៦-ព្រិន្ទបាលឯក	ឆាន់	ម៉ុនលីម	១៣៧៨៣៨	មេបញ្ជាការរង អត.អ.ធ បញ្ជូនសារកងពល
២៧-ព្រិន្ទបាលឯក	ស្រ៊ុន	ប៊ុលីន	២០៩៤៥៤	ប.ចលនូបត្ថម្ភ អ.ធ បញ្ជូនសារ កងពល
២៨-ព្រិន្ទបាលឯក	គាំ	ម៉ុនថន	២០៩៤៣៣	មេបញ្ជាការរង អត.អ.ធ ដឹកជញ្ជូន កងពល
២៩-ព្រិន្ទបាលឯក	អ៊ុំ	សុផល	០៦៥៧៩៣	មេបញ្ជាការរង អត.អ.ធ ដឹកជញ្ជូន កងពល
៣០-ព្រិន្ទបាលឯក	រម្យ	សារម៉ឿន	១៥៨៧៧៧	មេបញ្ជាការរង អត.អ.ធ ស្ពានថ្នល់ កងពល
៣១-ព្រិន្ទបាលឯក	ឈី	ពិសិដ្ឋ	២០៩៤៦៦	មេក្រុម អត.អ.ធ ស្ពានថ្នល់ កងពល
៣២-ព្រិន្ទបាលឯក	នៅ	លាក់	១៦១៦៩២	បុគ្គលិកវិស្វកម្ម អ.ធ ស្ពានថ្នល់ កងពល
៣៣-ព្រិន្ទបាលឯក	សុខ	ម៉ុន្នី	០៦៥៧៩៧	មេបញ្ជាការរង អត.អ.ធ ស្ពានថ្នល់កងពល
៣៤-ព្រិន្ទបាលឯក	ចាក	ពៅគុជ	២០៩៤០៨	មេបញ្ជាការរង អត.អ.ធការពារអាកាស កងពល
៣៥-ព្រិន្ទបាលឯក	សរ	ម៉ៅ	១៣៧៧៣៦	មេបញ្ជាការរង អត.អ.ធការពារអាកាស កងពល
៣៦-ព្រិន្ទបាលឯក	សៀវ	សារិន	២០៩៤៩៤	មេបញ្ជាការរង អត.អ.ធការពារអាកាស កងពល
៣៧-ព្រិន្ទបាលឯក	អន	ចាន់ណា	១៣៧៧៦៧	មេបញ្ជាការរង អត.អ.ធការពារអាកាស កងពល
៣៨-នាយចំណង់	នូវ	ជឿន	១៤២៦៩២	បុគ្គលិកពេទ្យ កងពល
៣៩-ព្រិន្ទបាលឯក	មាស	សាវុធ	១៤២៦៧៩	មេក្រុម អត.អ.ធ ការពារកងពល
៤០-ព្រិន្ទបាលឯក	យិន	ឌុច	១៤២៧០៣	មេបញ្ជាការរង អត.អ.ធការពារកងពល

៤១-ព្រិន្ទបាលឯក	ឋិត្យ	សាខន	២០៩៩១០	មេក្រុម អត.អ.ធ ការពារកងពល
៤២-ព្រិន្ទបាលឯក	តា	ដេត	១៣៧៨១៧	មេក្រុម អត.អ.ធ ស៊ើបការណ៍កងពល
៤៣-ព្រិន្ទបាលឯក	កែវ	ម៉ុនធឿន	០៦៥៨២៣	ប.ពេទ្យ អ.ធ ទី១ វរសេនាតូចលេខ ១១១
៤៤-ព្រិន្ទបាលឯក	ចាន់	សួរ	០៦៣០៣១	មេបញ្ជាការរង អត.អ.ធ ទី២ វ.តូចលេខ ១១១
៤៥-ព្រិន្ទបាលឯក	គង់	ម៉ុនធឿន	១៧៨៦៩៣	មេក្រុម អត.អ.ធ ទី១ វរសេនាតូចលេខ ១១១
៤៦-ព្រិន្ទបាលឯក	ម៉ែន	ណាត	១៥៨៨១៥	មេបញ្ជាការរង អត.អ.ធ ទី២ វ.តូចលេខ ១១១
៤៧-ព្រិន្ទបាលឯក	ឡើក	ខ្លា	១៥៨៨១៨	ប.ពេទ្យ អ.ធ គាំទ្រ វរសេនាតូច លេខ ១១១
៤៨-ព្រិន្ទបាលឯក	ម៉ុន	មួន	១៦៧៧១១	មេបញ្ជាការរង អគត្យាល់៨២ អធ.គាំទ្រ វ.តូចលេខ ១១២
៤៩-ព្រិន្ទបាលឯក	គាត	កែម	១៤២៨៧៥	មេក្រុម អ.គ២.អ.ធ.៥ វ.តូចលេខ ១១២
៥០-ព្រិន្ទបាលឯក	ឃុំ	លីឈាង	១៦១៧៨២	មេបញ្ជាការរង អ.គ១.អ.ធ.៦ វ.តូចលេខ ១១២
៥១-ព្រិន្ទបាលឯក	យ៉ាន	តួង	១៦៧៧១២	មេបញ្ជាការរង អ.គ២.អ.ធ.៦ វ.តូចលេខ ១១២
៥២-ព្រិន្ទបាលឯក	ម៉ុ	មាសសែនវណ្ណៈ	១៩០៦១១	មេក្រុម អ.គ ស៊ើបការណ៍
៥៣-ព្រិន្ទបាលឯក	ភ្នាំ	ឡុក	១៧៨៦៩៩	ប.វិស្វកម្ម ធគ.៦ វរសេនាតូច លេខ ១១២
៥៤-ព្រិន្ទបាលឯក	ខឹម	រ៉ែ	១៩០៦៦៣	មេក្រុម អ.គ៦.អ.ធ.៤ វ.តូចលេខ ១១២
៥៥-ព្រិន្ទបាលឯក	យិន	សំណាង	០៦៣៨៧៥	ប.ហិរញ្ញវត្ថុ វរសេនាតូចលេខ ១១៣
៥៦-ព្រិន្ទបាលឯក	ឡាច	ម៉ុនលី	១៧៨៧៥១	មេក្រុម អ.គ៤.អ.ធ.៨ វ.តូចលេខ ១១៣
៥៧-ព្រិន្ទបាលឯក	ម៉ាល់	សុគុណ	១៧៨៧៣៨	មេក្រុម អ.គ៤.អ.ធ.៩ វ.តូចលេខ ១១៣
៥៨-ព្រិន្ទបាលឯក	ហុង	ដារ៉ា	២០៩៤៣៧	មេបញ្ជាការអ.គ ស៊ើបការណ៍ វ.តូចលេខ ១១៤
៥៩-ព្រិន្ទបាលឯក	អ៊ុន	លីន	១៩០៥៤៥	ប.វិស្វកម្ម វរសេនាតូចលេខ ១១៣
៦០-ព្រិន្ទបាលឯក	ឈឹម	ឫទ្ធី	១៤២៦៨៧	បំរើការលេខាធិការដ្ឋានកងពល
៦១-ព្រិន្ទបាលឯក	អ៊ួន	ធារ៉ា	១៣៧៦០៦	បំរើការលេខាធិការដ្ឋានកងពល
៦២-ព្រិន្ទបាលឯក	អ៊ួន	រិទ្ធី	១៣៧៧១០	បំរើការលេខាធិការដ្ឋានកងពល
៦៣-ព្រិន្ទបាលឯក	ស៊ុម	ពៅ	១៤០៧៦៦	ប.វិស្វកម្ម អ.ធ.៧.វរសេនាតូច លេខ ១១៣
៦៤-ព្រិន្ទបាលឯក	សយ	រិត	១៧៨៧៦១	ប.បញ្ជូនសារ អ.ធ.៩.វរសេនាតូច លេខ ១១៣

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ចំនួន០៤រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន ក្នុងការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :-

ក-មេដាយសុវត្ថារា ថ្នាក់ សេនា :

១-ឯកឧត្តម **ឃួន សារ៉េត**	អគ្គលេខាធិការរង ក ក ជ
២-ឯកឧត្តម **វ៉ែន ទិរៈ**	អគ្គលេខាធិការរង ក ក ជ
៣-ឯកឧត្តម **សុត្រ សយ**	អគ្គលេខាធិការរង ក ក ជ

ខ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ :

-លោក **ស្រ៊ុន ដារិទ្ធិ**	ប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ចំនួន០៨រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចលើការងារស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

១-លោកស្រី **គង់ វណ្ណា** ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ក ក ជ

២-លោក **ហេង វិជ្ជា** ប្រធាននាយកដ្ឋានស្ថិតិ ទិន្នន័យ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក ក ជ

៣-លោក **គន សុពុទ្ធិ** អនុប្រធាននាយកដ្ឋាន កសិកម្ម ក ក ជ

៤-លោក **ជូ ប៊ុនហៀង** អនុប្រធាននាយកដ្ឋាន កសិកម្ម ក ក ជ

ខ-មេដាយប្រាក់ការងារ :

១-លោក **វង្ស សុខា** ប្រធានការិយាល័យស្ថិតិ ទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក ក ជ

២-លោក **ចេង ច័ន្ទពណ្ណរ៉ា** ប្រធានការិយាល័យផែនការ និងសហប្រតិបត្តិការអន្តរជាតិ ក ក ជ

៣-លោក **រ័ត្ន សុភ:** ប្រធានការិយាល័យអភិវឌ្ឍន៍ ជនបទ ក ក ជ

៤-លោក **គង់ ចន្ធី** ប្រធានការិយាល័យរដ្ឋបាល ក ក ជ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦២ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយស្ហាបនាជាតិ
៙
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ហាបនាជាតិ** ជូនលោក **ចាន់ ក្អុកឮ** ប្រធានសាខាក្រុមហ៊ុនប្រេងឥន្ធនៈ **TOTAL** ខេត្តកំពត ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងលូ ក្នុងទីរួមខេត្តកំពត ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៤១.០០០.០០០ រៀល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មេសា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៧១...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ចាន់ គុកលន់** សប្បុរសជន នៅ ខេត្តកំពង់ធំ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា នៅ *វិទ្យាល័យ ជា ស៊ីម ប្រឡាយ* ស្ថិតនៅ ឃុំប្រឡាយ ស្រុកស្ទោង និងសាងសង់ស្ពានអូរគ្រួច ស្ថិតក្នុងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ចំណាយអស់ថវិកាសរុបចំនួន ១២.០០០ ដុល្លារអាមេរិក ។

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញៈ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ [illegible] អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ-បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **សុខ ស៊ីឡុ** វរមន្ត្រី ថ្នាក់លេខ ៩ **ជាប្រធាននាយកដ្ឋានរដ្ឋបាល** នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

៣៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនសពលោក Che Shin YOO អតីតទីប្រឹក្សាបច្ចេកទេសក្រុមហ៊ុន KCI (Korea Consultants International) ដែលមានស្នាដៃល្អក្នុងការជួយស្ថាបនា ដំណាក់កាលដំបូង នៃកំណាត់ផ្លូវជាតិ លេខ ៥-៦ (ប៉ោយប៉ែត-សៀមរាប) និង ផ្លូវលេខ ៥៦-៦៨ (ស៊ីសូផុន-សំរោង-ក្រឡាញ់) រហូតដល់ធ្លាក់ខ្លួនឈឺជាទម្ងន់ នៅនឹងការដ្ឋានផ្ទាល់ និងបានទទួលមរណភាព នៅមន្ទីរពេទ្យ ក្រុងសេអ៊ូល កាលពីថ្ងៃទី២៥ ខែ មករា កន្លងទៅ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...២៧៣៧...អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឡាយ ត្លុក** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៤...សសរ

សេចក្តីសំរេច

ស្តីពីការបង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៥១៤ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៥១៥ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង

-បានឃើញសេចក្តីសំរេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម

-យោងតាមតំរូវការចាំបាច់

សំរេច

ប្រការ១ : បង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាមដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **វ៉ា គឹមហុង**	ទេសរដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម	ប្រធាន
២-ឯកឧត្តម **ឡុង វិសាលោ**	រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៣-ឯកឧត្តម **ម៉ុន សម**	រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៤-ឯកឧត្តម **ហួន សាវ៉ាង**	អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥-ឧត្តមសេនីយ៍ឯក **ឈុំ សុជាត**	នាយរងសេនាធិការ និងជានាយកទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ	សមាជិក
៦-ឯកឧត្តម **ឡាំ ជា**	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧-លោកជំទាវ **ក្មួយ ពិសី**	លេខាធិការ នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៨-ឯកឧត្តម **ម៉ុន ហ៊ាន**	អគ្គនាយកកិច្ចការបច្ចេកទេស និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ឡាវ និងថៃ ក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
៩-ឧត្តមសេនីយ៍ឯក**ចាន់ អ៊ាន**	ប្រធាននាយកដ្ឋានកណ្តាល ក្រសួងមហាផ្ទៃ	សមាជិក
១០-ឧត្តមសេនីយ៍ឯក**ទេព ចំរើន**	ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងការពារជាតិ	សមាជិក
១១-ឯកឧត្តម **អភិបាលខេត្ត**	កំពង់ចាម	សមាជិក
១២-ឯកឧត្តម **អភិបាលខេត្ត**	ស្វាយរៀង	សមាជិក
១៣-ឯកឧត្តម **អភិបាលខេត្ត**	ព្រៃវែង	សមាជិក
១៤-ឯកឧត្តម **អភិបាលខេត្ត**	កណ្តាល	សមាជិក

១៥-ឯកឧត្តម **អភិបាលខេត្ត**	តាកែវ	សមាជិក
១៦-ឯកឧត្តម **អភិបាលខេត្ត**	កំពត	សមាជិក
១៧-ឯកឧត្តម **អភិបាលខេត្ត**	ក្រចេះ	សមាជិក
១៨-ឯកឧត្តម **អភិបាលខេត្ត**	មណ្ឌលគិរី	សមាជិក
១៩-ឯកឧត្តម **អភិបាលខេត្ត**	រតនគិរី	សមាជិក
២០-ឧត្តមសេនីយ៍ **មេបញ្ជាការ**	យោធភូមិភាគ១	សមាជិក
២១-ឧត្តមសេនីយ៍ **មេបញ្ជាការ**	យោធភូមិភាគ២	សមាជិក
២២-ឧត្តមសេនីយ៍ **មេបញ្ជាការ**	យោធភូមិភាគ៣	សមាជិក
២៣-ឧត្តមសេនីយ៍ទោ **សេង សារី**	នាយសេនាធិការ និងជានាយការិយាល័យការពារព្រំដែនគោកទ័ពជើងគោក ក្រសួងការពារជាតិ	សមាជិក
២៤-លោក **អ៊ិត សុត្ថា**	ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់	សមាជិក
២៥-លោក **ឡាយ ទោហារិទ្ធ**	ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ	សមាជិក
២៦-ឧត្តមសេនីយ៍ត្រី **ពេជ្រ ជីវ័ន្ត**	ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ	សមាជិក
២៧-លោក **ហូ ពេជ្រមាលី**	អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	សមាជិក

ប្រការ២ : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម អាចបង្កើតអនុគណៈកម្មការបច្ចេកទេសចំរុះ ក្រុមប្រតិបត្តិការចំរុះ និងក្រុមបច្ចេកទេសចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក សំរាប់ធ្វើជាសេនាធិការ ។

ប្រការ៣ : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម មានភារកិច្ចដូចតទៅ :

-អនុវត្តឱ្យបានសំរេចជាស្ថាពរនូវសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និង

សាធារណរដ្ឋសង្គមនិយមវៀតណាម

-រៀបចំចាត់ចែងបែបបទផ្លូវច្បាប់និងបច្ចេកទេសសំរាប់ការងារខ័ណ្ឌសីមានិងបោះបង្គោលព្រំដែន

-រៀបចំចាត់ចែងតួនាទី ភារកិច្ច និងសមាសភាពរបស់អនុគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែន ក្រុមប្រតិបត្តិការចំរុះ និងក្រុមបច្ចេកទេសចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង

-ធ្វើការត្រួតពិនិត្យ ដោះស្រាយបញ្ហា និងឯកសារនានា ដែលក្រុមប្រតិបត្តិការ និង ក្រុមបច្ចេកទេសវាស់វែងជួបប្រទះ លើដីជាក់ស្តែង

-ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនសំរាប់រាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ៤ : គ្រប់សមាជិកនៃគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ។

ប្រការ៥ : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី នឹងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ៦ : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក នឹងត្រូវរំសាយទៅវិញនៅពេលណាដែលការងារអនុវត្តសន្ធិសញ្ញាដូចក្នុងប្រការ៣ ត្រូវបានចប់សព្វគ្រប់ ។

ប្រការ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័ន អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៧

-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ: ២៨១.........ប្រក.សហវ.បទ.ច.ម.ព

ប្រកាសអន្តរក្រសួង
ស្ដីពី
អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៧ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិស័យប្រៃសណីយ៍។

- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។
- បានឃើញប្រកាសលេខ 00៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។
- បានឃើញលិខិតលេខ ១១៥ស.ហ.វ.ម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។
- បានឃើញសារាចរណែនាំលេខ 00២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល ។
- បានឃើញការងារចាំបាច់របស់នាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និងទំនាក់ទំនងអន្តរជាតិ ។
- យោងកំណត់ហេតុអង្គប្រជុំអន្តរក្រសួង ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៥ ។

ស ម្រេ ច

ប្រការ ១ : ប្រកាសនេះមានគោលដៅគ្រប់គ្រង និងផ្តល់អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ជូនផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្របច្បាប់ ។

ប្រការ ២ : - អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ គឺជាអាជ្ញាប័ណ្ណដែលត្រូវផ្តល់ជូនផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ បន្ថែមលើសេវាប្រៃសណីយ៍ ដែលស្ថិតក្រោមអាជីវកម្មរបស់រដ្ឋ ដើម្បីជួយបំពេញនិងទ្រទ្រង់សេវាប្រៃសណីយ៍ និងបំរើតាមសំណូមពររបស់ប្រជាពលរដ្ឋ ។

- សេវាបញ្ញើឆាប់រហ័សអន្តរជាតិ គឺជាសេវាកម្មប្រៃសណីយ៍ទំនើបមួយដែលបានរៀបចំប្រព័ន្ធសេវាមានលក្ខណៈអន្តរជាតិ។ សេវានេះត្រូវបានធានានូវសុវត្ថិភាពចាប់តាំងពី ទទួល បញ្ជូន និងប្រគល់ដល់ដៃអ្នកទទួល មានការតាមដានជាប្រចាំ ដោយការកត់ត្រាតាមប្រព័ន្ធព័តិមានវិទ្យា និងមានអាទិភាពជាងបញ្ញើដទៃទៀត។

ប្រការ ៣ : គ្មានផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គលណាមួយ អាចធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដោយគ្មានអាជ្ញាប័ណ្ណ មានសុពលភាពដែលចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ឡើយ ។

ប្រការ ៤ : ផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដែលអាចធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិបាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ ឬបរទេស
- មានកាយសម្បទាគ្រប់គ្រាន់
- មានបទពិសោធន៍ខាងវិស័យប្រៃសណីយ៍
